សួស្តីឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ

HAPPY KHMER NEW YEAR

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អុន ព័ន្ធមុនីរ័ត្ន
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

សារជូនពរ
សូមគោរពជូន
ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អុន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ជាទីគោរព !

ក្នុងឱកាសដ៏មហានក្តីត្រេកអរ ដែលបានមកដល់ដោយសេចក្តីសោមនស្សរីករាយ ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ខាងមុខនេះ: តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ ខ្ញុំបាទនិងភរិយា សូមជូននូវសប្តសុសាធុការពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ ជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** សូមទទួលបាននូវសុខភាពល្អបរិបូរ: កម្លាំងកាយមាំមួន បញ្ញាញាណ រាងវៃ ជន្មាយុយឺនយូរ ដើម្បីរួមចំណែកជាមួយពលរដ្ឋាភិបាលក្នុងការដឹកនាំប្រទេសជាតិវិវត្តន៍ដែរ ដ្ឋានៈ ទៅការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងភាពសម្បូរសប្បាយរុងរឿង។

ឆ្លៀតក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ: យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវការគោរព និងកោតសរសើរយ៉ាងស្មោះ ចំពោះ: **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ដែលជាបញ្ញវន្តដ៏ធ្វើមមួយរូបរបស់កម្ពុជាដែលតែងតែយកអស់ កម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី ក្នុងការរៀបចំគោលនយោបាយសេដ្ឋកិច្ច និងការធ្វើកំណែទម្រង់នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ: លើកកម្ពស់ការពង្រឹងសមត្ថភាពស្ថាប័ន និងការកសាងសមិទ្ធផលសង្គមនានា ដើម្បីធ្វើឱ្យប្រទេសជាតិមានការរីកចម្រើន រឿនលឿនយ៉ាងឆាប់រហ័ស ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាប្រមុខដឹកនាំដ៏ឈ្លាសវៃ និងប៉ិនប្រសប់ ។

ជាចុងក្រោយទៀត តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ខ្ញុំបាទនិងភរិយា សូមបួងសួងចំពោះគុណបុណ្យព្រះតេជគុណ ត្រៃ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងណេក មានទេវតាធ្នាំ សូមព្រះអង្គតាមជួយបីបាច់ថែរក្សាការពារ និងប្រោះពុំនូវសប្តសុសាធុការពរជ័យ ជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** និង**លោកជំទាវ** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អុន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ១១ទុលនូវការគោរពដ៏ខ្ពស់ពីខ្ញុំបាទ។

ថ្ងៃព្រហស្បតិ៍ ១០រោចខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០២៦

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

នាយឧត្តមសេនីយ៍ ម៉ៅ សីហា

វិថីហ្សាតមីហ្ស៊ូ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរស័ព្ទលេខ០២៣ ៨៨៣ ២១៨ email: generalsec@mod.gov.kh